អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន
# ដែលបានចេញតាមសំណើរបស់ចៅក្រមជាតិនៃ អ.វ.ត.ក

ចៅក្រមជាតិដែលបានតែងតាំងឲ្យមកបំពេញការងានៅ អ.វ.ត.ក បានពិចារណាថា ការសម្រេចចិត្តរបស់ចៅក្រមអន្តរជាតិមិនចូលរួមក្នុងកិច្ចប្រជុំពេញអង្គនៅដំណាច់ខែនេះ នឹងកាន់តែពន្យារដំណើរការរបស់សាលាក្តីនេះ។

កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ចៅក្រមជាតិទាំងដប់ប្រាំរូបនៅ អ.វ.ត.ក បានដាក់ជូនលិខិតមួយច្បាប់ដើម្បីជាការឆ្លើយតបទៅនឹងលិខិត ចុះថ្ងៃទី០៣ ខែមេសា របស់សហការីអន្តរជាតិរបស់ខ្លួន ដែលក្នុងលិខិតនោះបានប្រកាសថា ពួកគាត់នឹងមិនចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គ ដែលបានកំណត់កាលបរិច្ឆេទនៅថ្ងៃទី៣០ ខែមេសា ដើម្បីអនុម័តលើសេចក្តីព្រាងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលនឹងបង្កលក្ខណៈឲ្យការជំនុំជម្រះបន្តដំណើរទៅមុខ ស្របតាមការរំពឹងទុករបស់ជនរងគ្រោះ នោះទេ។

នៅក្នុងការឆ្លើយតបទៅនឹងសំណើ សុំឲ្យដកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ចេញពីដំណើរការរបស់ អ.វ.ត.ក នោះ ចៅក្រមជាតិយល់ឃើញថា ការធ្វើបែបនេះពុំស្របនឹងខ្លឹមសារ និងស្មារតីរបស់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (ពិសេស មាត្រា ២១.៣) ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏ដូចជាគោលបំណងដើមនៅក្នុងការបង្កើតតុលាការនេះទេ។

ចៅក្រមជាតិកត់សម្គាល់ឃើញថា ទាំងសមាជិកជាតិ និងអន្តរជាតិនៃគណៈកម្មាធិការត្រួតពិនិត្យឡើងវិញបានដោះស្រាយបញ្ហាបច្ចេកទេសច្បាប់ទាំងអស់រួចហើយ។ ចៅក្រមជាតិចង្អុលបង្ហាញថា សោហ៊ុយ

សម្រាប់កាចុះបញ្ជីជាមួយគណៈមេធាវី មិនជាបញ្ហាដែលគ្របដណ្តប់ដោយវិធានផ្ទៃក្នុងនេះទេ ហើយហេតុដូច្នេះ ពុំគួរជាមូលហេតុដើម្បីពន្យារដល់ការអនុម័តរបស់ខ្លួន ដូចដែលបានជំទាស់ពីសំណាក់ចៅក្រមអន្តរជាតិទាំងអស់ នៅក្នុងលិខិត ចុះថ្ងៃទី៣ ខែមេសា របស់ពួកគាត់នោះឡើយ។

ចៅក្រមជាតិក៏សោកស្តាយចំពោះការសម្រេចចិត្តរបស់ចៅក្រមអន្តរជាតិ ដែលកំណត់ឱសានវាទដល់ BACK ទោះបីជាមានការផ្តល់យោបល់ពីសំណាក់ចៅក្រមជាតិម្តងហើយម្តងទៀតថា ទង្វើបែបនោះនឹងមិនរួមចំណែកដល់ដំណោះស្រាយជាវិជ្ជមានលើបញ្ហានេះក៏ដោយ។

លើសពីនេះទៀត ចៅក្រមជាតិបានរិះគន់ផ្នែកអង្គភាពគាំពារការការពារក្តីនៃ អ.វ.ត.ក ដែលមិនសកម្មនៅក្នុងការពិភាក្សា និងការចរចាជាមួយ BACK ដើម្បីឲ្យឈានដល់ការរៀបចំចាត់ចែងមួយ ដែលអាចទទួលយកបានទាំងអស់គ្នា។

ចៅក្រមជាតិបញ្ចប់លិខិតរបស់ខ្លួនដោយសង្ឃឹមថា ចៅក្រមអន្តរជាតិនឹងពិចារណាលើការសម្រេចចិត្តរបស់ខ្លួនឡើងវិញ និងចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដែលបានរៀបផែនការរួចហើយ។ ពួកគាត់បញ្ជាក់ថា ភារកិច្ចដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឲ្យទាំងចៅក្រមជាតិ និងអន្តរជាតិ គឺដើម្បីធ្វើឲ្យ អ.វ.ត.ក ទទួលបានជោគជ័យជាប្រវត្តិសាស្ត្រ គឺមិនមែនបរាជ័យនោះទេ។

**ភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧**